ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍ប្រចាំឆ្នាំ២០១៥

# ក្រុមការងារបច្ចេកទេសថ្នាក់ជាតបុរស ស្រលាញ់បុរស និងស្ត្រីបំប្លែងភេទ

រៀបចំដោយលេខាធិការដ្ឋានក្រុមការងារបច្ចេកទេសថ្នាក់ជាតបុរស
ស្រលាញ់បុរស និងស្ត្រីបំប្លែងភេទ

# សេចក្តីថ្លែងអំណរគុណ

តាំងនាមអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជាប្រធានក្រុមការងារបច្ចេកទេសថ្នាក់ជាតិបុរសស្រលាញ់បុរស និងស្ត្រីបំប្លែងភេទសូមសំដែងនូវសេចក្តីថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់គ្រប់បណ្តាក្រសួងពាក់ព័ន្ធ អង្គការដៃគូទាំងអស់ ក៏ដូចជាបណ្តាញដែលជាសមាជិកក្រុមការងារបច្ចេកទេសថ្នាក់ជាតិបុរសស្រលាញ់បុរស និងស្ត្រីបំប្លែងភេទ ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ការប្តេជ្ញាចិត្តខ្ពស់ និងកិច្ចខិតខំប្រឹងប្រែងយ៉ាងសកម្ម ក្នុងការចូលរួមសកម្មភាពការងាររបស់ក្រុមការងារបច្ចេកទេសថ្នាក់ជាតិកន្លងមក និងសូមអរគុណ និងសំដែងនូវការកោតសរសើរដល់ក្រុមលេខាធិការដ្ឋានក្នុងការរៀបចំផ្តើតរបាយការណ៍ប្រចាំឆ្នាំ២០១៥នេះឡើង។

**អគ្គលេខាធិការ**

**អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**



**ឯ.ឧ វេជ្ជ. តែង គន្ធី**

# មាតិកា


| | |
|---|---|
| សេចក្តីថ្លែងអំណរគុណ | i |
| មាតិកា | ii |
| ពាក្យបំព្រួញ | iii |
| សេចក្តីផ្តើម | ១ |
| សកម្មភាពសំខាន់ៗ ក្នុងឆ្នាំ២០១៥ | ៣ |
| ១. កិច្ចប្រជុំប្រចាំត្រីមាសជាមួយអ្នកផ្តល់សេវាសុខភាព | ៣ |
| ២. សកម្មភាពចុះអភិបាលកិច្ចទៅលើគុណភាពនៃការផ្តល់សេវាសុខភាព | ៣ |
| ៣. កិច្ចប្រជុំប្រចាំត្រីមាសក្រុមការងារបច្ចេកទេសថ្នាក់ជាតិបុរសស្រលាញ់បុរស និងស្ត្រីបំឡែងភេទ | ៤ |
| ៤. កិច្ចប្រជុំប្រចាំត្រីមាសក្រុមការងារបច្ចេកទេសថ្នាក់ក្រោមជាតិបុរសស្រលាញ់បុរស និងស្រីស្រស់ | ៥ |
| ៥. បរិយាកាសគាំទ្រ ក្នុងការជំរុញអោយក្រុមបុរសស្រលាញ់បុរស និងស្ត្រីបំឡែងភេទ មានការប្រើប្រាស់ស្រោមអនាម័យ១០០% | ៦ |
| ៦. យុទ្ធនាការបញ្ឈប់ការរើសអើង និងមាក់ងាយ នៅលើក្រុមបុរសស្រលាញ់បុរស និងស្ត្រីបំឡែងភេទ ក្នុងប្រទេសកម្ពុជា | ៧ |
| ៧. ពង្រឹងសមត្ថភាពដៃគូពាក់ព័ន្ធក្នុងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ក្នុងចំណោមក្រុមបុរសស្រលាញ់បុរស និងស្ត្រីបំឡែងភេទ | ៨ |
| ឧបសគ្គដែលបានជួបប្រទះ និងដំណោះស្រាយ | ៩ |
| មេរៀនជាបទពិសោធន៍ | ៩ |
| អនុសាសន៍ | ៩ |
| ផែនការប្រចាំឆ្នាំ២០១៦ | ១០ |
| ឧបសម្ព័ន្ធ១៖ ការប៉ាន់ស្មានចំនួនបុរសស្រលាញ់បុរស (ចន្លោះអាយុ១៥-៤៩ឆ្នាំ) នៅក្នុងប្រទេសកម្ពុជា ឆ្នាំ២០១៤ | |
| ឧបសម្ព័ន្ធ២៖ ចំនួនក្រុមបុរសស្រលាញ់បុរស និងស្រីស្រស់ គ្របដណ្តប់ដោយអង្គការដៃគូ ឆ្នាំ២០១៥ | |

# ពាក្យបំព្រួញ

| | |
|---|---|
| ART | ការព្យាបាលដោយឱសថប្រឆាំងនឹងមេរោគអេដស៍ |
| AHF | អង្គការថែទាំសុខភាពអ្នកជំងឺអេដស៍ នៅកម្ពុជា |
| CSSD | អង្គការសហគមន៍ដើម្បីសេវាសង្គមនិងអភិវឌ្ឍន៍ |
| CPN+ | បណ្ដាញអ្នករស់នៅជាមួយមេរោគអេដស៍កម្ពុជា |
| FHI360 | អង្គការអេសអេច អាយ360 |
| Flagship | សម្ព័ន្ធផ្លាកស៊ីប |
| KHANA | អង្គការខាណា |
| KHEMERA | អង្គការខេមរា |
| MEC | អង្គការវេជ្ជសាស្ត្រក្នុងក្ដីសង្ឃឹមកម្ពុជា |
| MHC | អង្គការសុខភាពបុរសកម្ពុជា |
| MHSS | អង្គការសេវាសង្គមសុខភាពបុរស |
| MSM | បុរសស្រលាញ់បុរស |
| NMSMTGTWG | ក្រុមការងារបច្ចេកទេសបុរសស្រលាញ់បុរស និងអ្នកបំប្លែងភេទថ្នាក់ជាតិ |
| NAA | អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ |
| NCHADS | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ |
| PSK | អង្គការខ្មែរបំរើសុខភាពប្រជាជន |
| Pre-ART | ការព្យាបាលមុនការព្យាបាលដោយឱសថប្រឆាំងនឹងមេរោគអេដស៍ |
| RHAC | សមាគមន៍ថែទាំសុខភាពគ្រួសារកម្ពុជា |
| SIT | អង្គការជំនួយក្មេងជំទង់ក្រីក្រ |
| TWG | ក្រុមការងារបច្ចេកទេស |
| UNAIDS | កម្មវិធីរបស់សហប្រជាជាតិរួមគ្នាស្ដីពីមេរោគអេដស៍/ជម្ងឺអេដស៍ |
| Transgender | អ្នកបំប្លែងភេទ ឬស្រីស្រស់ |
| USAID | ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីការអភិវឌ្ឍន៍អន្តរជាតិ |
| VCCT | ការផ្ដល់ប្រឹក្សា និងធ្វើតេស្តឈាមដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់ |

# សេចក្តីផ្តើម

តាមការប៉ាន់ប្រមាណស្ថានភាពទូទៅនៃការរីករាលដាលនៃមេរោគអេដស៍/ជំងឺអេដស៍នៅកម្ពុជានាពេលបច្ចុប្បន្ននេះបានបង្ហាញនូវការធ្លាក់ចុះនូវអត្រាប្រេវ៉ាឡង់មេរោគអេដស៍ ក្នុងចំណោមប្រជាជនទូទៅដែលមានអាយុចន្លោះពី១៥ឆ្នាំ ដល់៤៩ឆ្នាំ មកត្រឹមប្រមាណ ០.៦% ក្នុងឆ្នាំ២០១៥។ ទោះបីជាយ៉ាងណាក៏ដោយ តាមការសិក្សាបានបញ្ជាក់ថាអត្រាប្រេវ៉ាឡង់មេរោគអេដស៍នៅតែខ្ពស់ក្នុងចំណោមក្រុមប្រជាជនប្រឈមមុខសំខាន់ៗមានដូចជា ក្រុមស្រ្តីធ្វើការនៅតាមគ្រឹះស្ថានកំសាន្ត មានប្រមាណជា១៤% ក្នុងចំណោមអ្នកដែលមានដៃគូរួមភេទលើសពី ៧នាក់ក្នុង ១សប្តាហ៍[1] ក្រុមបុរសស្រឡាញ់បុរស មានប្រមាណជា២.៣%[2] ក្រុមស្រ្តីបំប្លែងភេទមាន៥.៩%[3] និងក្រុមអ្នកចាក់គ្រឿងញៀន មានប្រមាណ២៤,៨%[4]។

តាមការប៉ាន់ស្មានដែលធ្វើឡើងក្នុងឆ្នាំ ២០១៤ ចំនួនបុរសស្រលាញ់បុរសក្នុងប្រទេសកម្ពុជាប្រមាណជា ៣១000 នាក់ ក្នុងនោះមានប្រមាណជា ៥២% រស់នៅតំបន់ប្រជុំជន និងប្រមាណជា ៨៩% (២៧៥០០) សកម្មក្នុងការរួមភេទ និងប្រមាណតែ ២០០០០ នាក់ប៉ុណ្ណោះជាបុរសស្រលាញ់បុរសដែលអាចរកជួបបាន។ តាមរយៈការសិក្សានេះក៏បង្ហាញផងដែរថា ៨៨,៦%នៃបុរសស្រលាញ់បុរសរាយការណ៍ថាធ្លាប់បានរួមភេទតាមរន្ធគូថក្នុងរយៈពេល ១២ខែកន្លងមក ហើយមានប្រមាណជា ២/៣ ធ្លាប់រួមភេទក្នុងតាមរន្ធគូថក្នុងរយៈពេល ១ខែចុងក្រោយ។ ក្នុងចំណោមអ្នកដែលរាយការណ៍ថាមានការរួមភេទក្នុងរយៈពេល ៦ខែកន្លងមក មានតែ ៦៩,៤%ប៉ុណ្ណោះ ដែលតែងតែប្រើប្រាស់ស្រោមអនាម័យរាល់ពេលរួមភេទ ហើយមានតែ ៦៦,៦% បានធ្វើតេស្តឈាមរកមេរោគអេដស៍ និង ៤៩,៣% ធ្លាប់បានពិនិត្យរកជម្ងឺកាមរោគ ក្នុងរយៈពេល ៦ខែកន្លងទៅ។ តាមការសិក្សាឆ្នាំ ២០១៦ក្នុងចំណោមក្រុមស្រ្តីបំប្លែងភេទ បង្ហាញថាមានប្រមាណជា ៨៦% ធ្លាប់រួមភេទជាមួយបុរសតាមរន្ធគូថក្នុងរយៈពេល៣ខែចុងក្រោយ ហើយមានតែ ៦១,៩%តែប៉ុណ្ណោះដែលបានប្រើប្រាស់ស្រោមអនាម័យពេលរួមភេទតាមរន្ធគូថចុងក្រោយបង្អស់ និង៤៤,៣%ប៉ុណ្ណោះដែលធ្លាប់បានធ្វើតេស្តរកមេរោគអេដស៍ ក្នុងអំឡុងពេល៦ខែមុន។

ក្រៅពីបញ្ហាប្រឈមខាងលើ ក្រុមបុរសស្រលាញ់បុរស និងក្រុមស្រ្តីបំប្លែងភេទទទួលរងនូវការមាក់ងាយ រើសអើង ការរំលោភបំពានផ្សេងៗដែលធ្វើអោយពួកគេមានការប្រឈមកាន់តែខ្លាំងក្នុងការឆ្លងនឹងមេរោគអេដស៍ និងជាឧបសគ្គចំពោះការទទួលបានសេវាចាំបាច់នានា ដែលពួកគេត្រូវការ។

---

1 HSS 2010
2 IBBS MSM 2014
3 IBBS TG 2016
4 IBBS PWUD/PWID 2012

**បុរសស្រលាញ់បុរស** នៅក្នុងពាក្យស័ព្ទដែលត្រូវបានគេប្រើជាទូទៅនៅផ្នែកសុខភាពសារធារណៈ បានឲ្យនិយមន័យគឺជាការប្រព្រឹត្តផ្លូវភេទមួយបែបដែលកើតឡើងរវាងបុរសម្នាក់ជាមួយនិងបុរសម្នាក់ផ្សេងទៀតដោយមិនគិតពីអត្តសញ្ញាណនៃភេទ ការជំរុញឲ្យប្រទ្បូកក្នុងការរួមភេទ ឬអត្តសញ្ញាណកម្មដែលកំណត់ជាមួយ ឬដោយសហគមន៍ ជាពិសេសណាមួយឡើយ។ ពាក្យបុរស និងភេទត្រូវបានបកស្រាយពន្យល់ខុសៗគ្នាទៅតាមវប្បធម៌ និងសង្គមដែលបុគ្គលរស់នៅ និងបានចូលរួម។ ជាលទ្ធផលពាក្យបុរសរួមភេទជាមួយបុរសមានន័យយ៉ាងទូលំទូលាយហើយប្រែប្រួលទៅតាមទីកន្លែង និងបរិបទដែលមានទំនាក់ទំនងរវាងបុរស និងបុរសនោះបានកើតឡើង។

# សកម្មភាពសំខាន់ៗ ក្នុងឆ្នាំ២០១៥

## ១. កិច្ចប្រជុំប្រចាំត្រីមាសជាមួយអ្នកផ្តល់សេវាសុខភាព

កិច្ចប្រជុំប្រចាំត្រីមាសត្រូវបានរៀបចំឡើងជាមួយអ្នកផ្តល់សេវាសុខភាព ដូចជាមណ្ឌលសុខភាព គ្លីនិកសុខភាពគ្រួសារ គ្លីនិកអង្គការរ៉ាក់ គ្លីនិកសមាគមឈូកស គ្លីនិកអង្គការMEC និងអង្គការមិត្តសំឡាញ់ ដើម្បីធានាថាអ្នកផ្តល់សេវាមិនមានការរើសអើង និងមាក់ងាយទៅលើបុរសស្រលាញ់បុរស និងស្រ្តីបំឡែងភេទ។ កិច្ចប្រជុំនេះដឹកនាំដោយឯកឧត្តមប្រធានក្រុមការងារ



សកម្មភាពប្រជុំឯកឧត្តមអគ្គលេខាធិការជាមួយ អ្នកផ្តល់សេវានិងក្រុមប្រឈមមុខខ្ពស់

បច្ចេកទេស ដោយផ្តោតសំខាន់ទៅលើការធ្វើតេស្តឈាមដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់ ការពិនិត្យនិងព្យាបាលជំងឺកាមរោគ អោយបានជាប់លាប់ និងការទៅទទួលសេវាឱសថប្រឆាំងនឹងមេរោគអេដស៍។

## ២. សកម្មភាពចុះអភិបាលកិច្ចទៅលើគុណភាពនៃការផ្តល់សេវាសុខភាព



សកម្មភាពក្រុមកាងារថ្នាក់ជាតិចុះសួរសុខទុក្ខ អ្នកជំងឺអេដស៍នៅខេត្តសៀមរាប

ក្រុមការងារបច្ចេកទេសថ្នាក់ជាតិជាមួយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍មជ្ឈមណ្ឌល ជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ និងអង្គការដៃគូបានចុះអភិបាលកិច្ច ដើម្បីពិនិត្យមើលលើការអនុវត្តន៍កម្មវិធីបទអន្តរាគមន៍បង្ការទប់ស្កាត់ការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍ ក្នុងការឆ្លើយតបចក្ខុវិស័យអង្គការសហប្រជាជាតិ UNAIDS “សូន្យបី” (គ្មានការឆ្លងមេរោគអេដស៍ថ្មី គ្មានការស្លាប់ដោយសារជំងឺអេដស៍ និង គ្មានការរើសអើង) និងយុទ្ធវិធី ៩០ ៩០ ៩០ ក្នុងឆ្នាំ២០២០។ ក្នុងសកម្មភាពចុះអភិបាលកិច្ចនៅសហគមន៍ក្រុមការងារបច្ចេកទេសបានស្នើរទៅដល់អង្គការជាដៃគូថា

## ៣. កិច្ចប្រជុំប្រចាំត្រីមាសក្រុមការងារបច្ចេកទេសថ្នាក់ជាតិបុរសស្រលាញ់បុរស និងស្ត្រីបំប្លែងភេទ



ក្រុមការងារបច្ចេកទេសថ្នាក់ជាតិ ក្រោមការដឹកនាំដោយឯកឧត្តម វេជ្ជបណ្ឌិត តែង គន្ធី អគ្គលេខាធិការនិងជាប្រធានក្រុមការងារបច្ចេកទេសថ្នាក់ជាតិ ក្រោមការគាំទ្រថវិកាដោយអង្គការសម្ព័ន្ធគម្រោង Flagship មានអង្គការ KHANA FHI360 និងPSK បានរៀបចំកិច្ចប្រជុំប្រចាំត្រីមាសជាមួយសមាជិកក្រុមការងារបច្ចេកទេស។ កិច្ចប្រជុំក្រុមការងារបច្ចេក ទេសថ្នាក់ជាតិ នេះមានការចូលរួមពីសមាជិកក្រុមការងារបច្ចេកទេស គ្រប់បណ្ដាក្រសួងពាក់ព័ន្ធ និងអាជ្ញាធរដែនដី ដើម្បីពិនិត្យមើលបច្ចុប្បន្នភាពជោគជ័យ និងឧបសគ្គក្នុងការចូលរួមបទអន្តរាគមន៍លើក្រុមបុរសស្រលាញ់បុរស និងស្ត្រីបំប្លែងភេទ និងពិនិត្យមើល និងរួមគ្នាដោះស្រាយឧបសគ្គនានា ដែលរាំងស្ទះដល់បទអន្តរាគមន៍ និងការអនុវត្តន៍ផែនការក្រុមការងារបច្ចេកទេសថ្នាក់ជាតិ និងរៀបចំយុទ្ធសាស្រ្តថ្នាក់ក្រោមជាតិ ដើម្បីឆ្លើយតបបទអន្តរាគមលើក្រុមបុរសស្រលាញ់បុរសនិងក្រុមស្ត្រីបំប្លែងភេទ ក្នុងប្រទេសកម្ពុជា។

## ៤. កិច្ចប្រជុំប្រចាំត្រីមាសក្រុមការងារបច្ចេកទេសថ្នាក់ក្រោមជាតិបុរសស្រលាញ់បុរស និងស្រីស្រស់

ក្រុមការងារបច្ចេកទេសថ្នាក់ជាតិ រួមសហការជាមួយក្រុមការងាថ្នាក់ក្រោមជាតិបុរសស្រលាញ់បុរស និងស្រីស្រស់ និងអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជម្ងឺអេដស៍សើស្បែក និងកាមរោគ និងអង្គការជាដៃគូ បានរៀបចំកិច្ចប្រជុំប្រចាំត្រីមាសជាមួយបណ្ដាញស្រីស្រស់ អាជ្ញាធរមូលដ្ឋាន និងសហគមន៍ ចំនួនប្រមាណ ៥៥នាក់ ដើម្បីផ្លាស់ប្ដូរយោបល់ក្នុងការជំរុញអោយក្រុមគោលដៅទៅទទួលសេវាសុខភាព និងពិនិត្យមើលបច្ចុប្បន្នភាព និងឧបសគ្គក្នុងការធ្វើបទអន្តរាគមន៍បង្ការការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍ ក្នុងចំណោមក្រុមស្រីស្រស់នៅខេត្តសៀមរាប។

កិច្ចប្រជុំនេះដឹកនាំដោយ ឯកឧត្តមប្រធានក្រុមការងារ រួមជាមួយតំណាងមកពីក្រសួងការពារជាតិ ក្រសួងសង្គមកិច្ច ក្រសួងមហាផ្ទៃ អភិបាលរងក្រុងខេត្តសៀមរាប លេខាធិការដ្ឋាន អាជ្ញាធរមូលដ្ឋាន តំណាងក្រុមប្រឈមមុខខ្ពស់ និងតំណាងស្រីស្រស់

ដោយមានឧបត្ថម្ភថវិកាពីទីភ្នាក់ងារសហរដ្ឋអាមេរិក(USAID) តាមរយៈអង្គការសម្ព័ន្ធ Flagship និងសហការជាមួយអង្គការសុខភាពបុរសកម្ពុជា (MHC)។





រូបភាព៖សកម្មភាពកិច្ចប្រជុំប្រចាំត្រីមាសក្រុមការងារថ្នាក់ក្រោមជាតិនៅខេត្តសៀមរាប

## ៥. បរិយាកាសគាំទ្រ ក្នុងការជំរុញអោយក្រុមបុរសស្រលាញ់បុរស និងស្ត្រីបំឡែងភេទមានការប្រើប្រាស់ស្រោមអនាម័យ១00%

អគ្គលេខាធិការនៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងក្រុមលេខាធិការដ្ឋានបានចូលរួមយុទ្ធនាការទិវានៃក្តីស្រឡាញ់នៅរាជធានីភ្នំពេញ ដើម្បីលើកទឹកចិត្តក្រុមប្រឈមមុខខ្ពស់ក្នុងការប្រើប្រាស់ស្រោមអនាម័យ ការពារការឆ្លងមេរោគអេដស៍ និងចូលរួមផ្សព្វផ្សាយទៅដល់សហគមន៍ និងលើកទឹកចិត្តអោយពួកគាត់ប្រើប្រាស់ស្រោមអនាម័យ១០០%រាល់ការរួមភេទ។ ក្នុងនោះដែរអគ្គលេខាធិការនៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងក្រុមលេខាធិការដ្ឋានបានចុះអភិបាលកិច្ចប្រចាំត្រីមាសជាមួយអង្គការដៃគូនៅក្នុងសហគមន៍ និងកន្លែងផ្តល់សេវាកំសាន្ត ដើម្បីពិនិត្យមើលការអនុវត្តន៍ប្រកាស០៦៦នៅកន្លែងធ្វើការ។



ពិពណ៌ស្រោមអនាម័យនៅសហគមន៍

## ៦. យុទ្ធនាការបញ្ឈប់ការរើសអើង និងមាក់ងាយ នៅលើក្រុមបុរសស្រលាញ់បុរស និងស្ត្រីបំប្លែងភេទ ក្នុងប្រទេសកម្ពុជា

អគ្គលេខាធិការ និងក្រុមការងារបច្ចេកទេសថ្នាក់ជាតិបុរសស្រលាញ់បុរស និងស្ត្រីបំប្លែងភេទ ចូលរួមយុទ្ធនាការបញ្ឈប់ការរើសអើង និងមាក់ងាយ លើក្រុមបុរសស្រលាញ់បុរស និងស្ត្រីបំប្លែងភេទនៅរាជធានីភ្នំពេញ និងខេត្តសៀមរាប តាមរយៈចូលរួមសំអាតទីក្រុង និងរុក្ខទិវាជាមួយអភិបាលខណ្ឌដូនពេញ អភិបាលរងក្រុងសៀមរាប ស្នងការខេត្ត ចៅសង្កាត់ ប៉ូលីសមូលដ្ឋាន និងក្រុមគ្រួសារអ្នកដែលស្រលាញ់ភេទដូចគ្នា ក្នុងការបញ្ឈប់ការរើសអើងនិងមាក់ងាយព្រមទាំងជំរុញលើកទឹកចិត្តពីអាជ្ញាធមូលដ្ឋានដល់ក្រុមបុរសស្រលាញ់បុរស និងស្ត្រីបំប្លែងភេទ ទៅទទួលសេវាដោយមិនមានការភ័យខ្លាចពីការរើសអើង និងមាក់ងាយពីអ្នកផ្តល់សេវាសុខភាព។






រូបភាព៖ យុទ្ធនាការបញ្ឈប់ការរើសអើង និងការមាក់ងាយលើក្រុមបុរសស្រលាញ់បុរស និងស្ត្រីបំប្លែងភេទ

## ៧. ពង្រឹងសមត្ថភាពដៃគូពាក់ព័ន្ធក្នុងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ក្នុងចំណោមក្រុមបុរសស្រលាញ់បុរស និងស្ត្រីបំប្លែងភេទ

ក្រុមការងារបច្ចេកទេសថ្នាក់ជាតិបុរសស្រលាញ់បុរស និងស្រីស្រស់ រួមជាមួយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ សើស្បែក និងកាមរោគ និងអង្គការជាដៃគូ បានពង្រឹងការអនុវត្តន៍បទអន្តរាគមន៍បង្ការមេរោគអេដស៍ និងជំងឺអេដស៍ ក្នុងចំណោមក្រុមបុរសស្រលាញ់បុរស និងស្ត្រីបំប្លែងភេទ តាមរយៈការផ្តល់បច្ចេកទេសរៀបចំកិច្ចប្រជុំប្រចាំខែ និងត្រីមាស ដើម្បីធ្វើការផ្លាស់ប្តូរបទពិសោធន៍ ដូចជាអ្នកផ្តល់សេវា ម្ចាស់សេវា និងអាជ្ញាធរដែនដី ក្នុងការជំរុញអោយក្រុមបុរសស្រលាញ់បុរស និងស្ត្រីបំប្លែងភេទទៅទទួលសេវាពិនិត្យ និងព្យាបាលជំងឺកាមរោគ ការធ្វើតេស្តឈាមដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់។

## ឧបសគ្គដែលបានជួបប្រទះ និងដំណោះស្រាយ

ការមកទទួលសេវានៅមានកម្រិតនៅឡើយដោយសារក្រុមគោលដៅមួយចំនួនមិនមានលទ្ធភាពក្នុងការមកទទួលសេវា។ ក្រុមគោលដៅខ្លះមិនហ៊ានមកទទួលសេវា និងមានការចល័តពីកន្លែងមួយទៅកន្លែងមួយ។ កង្វះថវិកា ឬការកាត់បន្ថយថវិកាជំនួយក្នុងការអនុវត្តន៍រាល់សកម្មភាពប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍ ក្នុងចំណោមក្រុមបុរសស្រលាញ់បុរស និងស្ត្រីបំប្លែងភេទ គឺជាកង្វល់ដ៏ធំធេងសម្រាប់អង្គការដែលជាដៃគូសហប្រតិបត្តិការនានា។ អ្នកជំងឺមួយចំនួនមិនអាចមកទទួលយកឱសថប្រឆាំងនឹងមេរោគអេដស៍ តាមការណាត់ជួបរបស់គ្រូពេទ្យ មូលហេតុដោយសារពួកគេមិនទាន់យល់ច្បាស់ពីសុខភាព មិនមានពេលគ្រប់គ្រាន់ និងជាប់ប្រកបរបរចិញ្ចឹមមជីវិត និងចំណាកស្រុក។ សេវាសុខភាពសំរាប់ក្រុមបុរសស្រលាញ់បុរស និងអ្នកបំប្លែងភេទមិនទាជន់មានភាពទូលំទូលាយគ្រប់បណ្តាររាជធានី ខេត្ត។ជាពិសេសការព្យាបាលអកម៉ូនទៅលើក្រុមស្រីស្រស់(អ្នកបំប្លែងភេទ) ក្រុមស្រីស្រស់នៅមានការចាប់ពីសំណាក់ប៉ូលីស ដោយពួកគាត់សំអាងថាក្រុមនេះធ្វើអោយខូចសណ្តាប់ធ្នាប់សាធារណះដែលធ្វើអោយក្រុមការងារអប់រំនៅក្នុងសហាគមន៍ពិបាកក្នុងការណាត់ជួបផ្តល់សារអប់រំនិងបញ្ជូនពួកទៅពិនិត្យសុខភាព។ គោលនយោបាយភូមិឃុំមានសុវត្ថភាពធ្វើអោយប៉ះពាល់ការប្រមូលក្រុមគោលដៅមកអប់រំនឹងធ្វើក្រុមពិភាក្សា

## មេរៀនជាបទពិសោធន៍

សហាការជាមួយអង្គការដៃគូក្នុងការបញ្ជូនក្រុមគោលដៅអោយមកទទួលសេវាកាន់តែច្រើន។ ជ្រើសរើសអ្នកផ្តល់ប្រឹក្សាជាបុរសស្រលាញ់បុរស និងស្រីស្រស់ ងាយស្រួលក្នុងការទំនាក់ទំនងជាមួយក្រុមបុរសស្រលាញ់បុរស និងស្រីស្រស់ ដែលលាក់មុខ។ ក្រុមការងារលេខាធិការដ្ឋានបុរសស្រលាញ់បុរស ក្រុមការងារបច្ចេកទេសថ្នាក់ជាតិនិងក្រុមការងារបុរសស្រលាញ់បុរសថ្នាក់ក្រោមជាតិជាមួយក្រសួងពាក់ព័ន្ធ អ្នកផ្តល់សេវា អាជ្ញាធរដែនដី និងក្រុមគ្រួសារបុរសស្រឡាញ់បុរស និងស្រីស្រស់ ជាអ្នកពាក់ពន្ធ័ក្នុងការជំរុញក្រុមគោលដៅទៅទទួលសេវានិងបញ្ឈប់ការមាក់ងាយនិងការរើសអើងទៅលើក្រុមបុរសស្រលាញ់បុរសនិងស្រីស្រស់ ។

# អនុសាសន៍

- ស្នើអង្គការជាដៃគូ ពិសេសអង្គការដែលអនុវត្តផ្ទាល់នៅសហគមន៍ គួររៀបចំសកម្មភាពសង្គម ដូចជាការចូលរួមធ្វើអនាម័យទីសាធារណៈ ក៏ដូចជាការជួយសង្គមតាម រយៈសកម្មភាពផ្សេងៗ។ រាល់សកម្មភាពទាំងនោះត្រូវសុំការអនុញ្ញាត្តិពីអាជ្ញាធរមូលដ្ឋានជាមុន។
- គួររៀបចំផែនការសកម្មភាពស្នើសុំថវិកាជាតិក្នុងការអនុវត្តន៍រាល់សកម្មភាពប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍ ក្នុងចំណោមក្រុមបុរសស្រលាញ់បុរស និងស្ត្រីបំប្លែងភេទ។
- ម្ចាស់ជំនួយត្រូវតែបន្តផ្តល់ជំនួយគាំទ្រដល់ អង្គការ សមាគមន៍ បណ្តាញ ដើម្បីឆ្លើយតបយុទ្ធសាស្ត្រ ៩០ ៩០ ៩០ ដល់ ឆ្នាំ២០២០ និងឈានឆ្ពោះទៅរកការលុបបំបាត់ការឆ្លងថ្មីនៃមេរោគអេដស៍ត្រឹមឆ្នាំ ២០២៥។
- ក្រុមការងារលេខាធិការដ្ឋាន និងក្រុមការងារបច្ចេកទេសថ្នាក់ជាតិបុរសស្រលាញ់បុរស និងស្ត្រីបំប្លែងភេទ គួរមានលក្ខណៈសកម្មក្នុងការសម្របសម្រួលការងារ និងដោះស្រាយបញ្ហាឧបសគ្គនានា ទាក់ទងនឹងបទអន្តរាគមន៍ឆ្លើយតបនឹងមេរោគអេដស៍ក្នុងចំណោមបុរសស្រលាញ់បុរស និងស្ត្រីបំប្លែងភេទ។

# ផែនការប្រចាំឆ្នាំ២០១៦

យុទ្ធសាស្ត្រទី១:បង្ការការឆ្លងមេរោគអេដស៍ថ្មីក្នុងក្រុមបុរសស្រលាញ់បុរស និងស្រីស្រស់
គោលដៅទី១:បង្កើនការប្រើប្រាស់សេវាសុខភាពដោយគ្មានការរើសអើងនិងមាក់ងាយដល់ក្រុមបុរសស្រលាញ់បុរស និងស្រីស្រស់

| | |
|---|---|
| ១ | សម្របសម្រួលកិច្ចប្រជុំបង្កើនការប្រើប្រាស់សេវាមេរោគអេដស៍ជាមួយសេវាសុខភាព អង្គការដៃគូ និងស្ថាប័នពាក់ព័ន្ធ |
| ២ | ចុះអភិបាលកិច្ចទៅលើគុណភាពនៃការផ្តល់សេវាសុខភាព |
| ៣ | រៀបចំកិច្ចប្រជុំផ្តល់យោបល់ និងវាយតម្លៃបន្ទាប់ពីចុះអភិបាលកិច្ចមកពិភាក្សាជាមួយក្រុមការងារលេខាធិការដ្ឋាន |
| ៤ | រៀបចំកិច្ចប្រជុំសម្របសម្រួលថ្នាក់ក្រោមជាតិ (ថ្នាក់មូលដ្ឋាន) ដល់អ្នកផ្តល់សេវា គ្រូសារ និងអាជ្ញាធរដែនដី (ការរើសអើង និងការទទួលសេវាសុខភាព) |

យុទ្ធសាស្ត្រទី២:បង្កើត និងធានានិរន្តភាពបរិយាកាសគាំទ្រកម្មវិធីបង្ការមេរោគអេដស៍ និងជំងឺអេដស៍ និងកាមរោគសម្រាប់ក្រុមបុរសស្រលាញ់បុរស និងស្រីស្រស់
គោលដៅទី២:បង្កើនការសហការ និងសម្របសម្រួលគ្រប់ដៃគូទាំងអស់

| | |
|---|---|
| ១ | រៀបចំវគ្គបណ្តុះបណ្តាលស្តីពីការចូលរួមដល់ថ្នាក់ដឹកនាំ និងមន្ត្រីពាក់ព័ន្ធក្នុងកម្មវិធីបង្ការមេរោគអេដស៍ និងជំងឺអេដស៍ ក្នុងចំណោមក្រុមបុរសស្រលាញ់បុរស និងស្រីស្រស់ តាមរយៈក្រសួងព័ត៌មាន |
| ២ | រៀបចំវគ្គពង្រឹងសមត្ថភាពដល់បណ្តាញបុរសស្រលាញ់បុរស និងស្រីស្រស់ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ |
| ៣ | សម្របសម្រួលជាមួយដៃគូពាក់ព័ន្ធក្នុងការពង្រីកសេវាបង្ការ ថែទាំ និងគាំទ្រ ដល់ក្រុមបុរសស្រលាញ់បុរស និងស្រីស្រស់ |
| ៤ | រៀបចំកិច្ចប្រជុំសម្របសម្រួលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ស្តីពីការកាត់បន្ថយការរើសអើង និងមាក់ងាយ ដើម្បីពង្រឹងការអនុវត្តន៍បទអន្តរាគមន៍បង្ការមេរោគអេដស៍ និងជំងឺអេដស៍ ក្នុងចំណោមក្រុមបុរសស្រលាញ់បុរស ស្រីស្រស់ |
| ៥ | បង្កើតវេទិកាជាមួយសារព័ត៌មាន ដើម្បីកាត់បន្ថយការរើសអើងក្រុមបុរសស្រលាញ់បុរស និងស្រីស្រស់ |
| ៦ | រៀបចំវគ្គបណ្តុះបណ្តាលពិគ្រោះយោបល់ស្តីពីយែនឌ័រដល់ក្រុមការងារលេខាធិការដ្ឋាន និងក្រុមការងារថ្នាក់ជាតិ |

យុទ្ធសាស្រ្តទី៣:ពង្រឹងសមត្ថភាពដៃគូពាក់ព័ន្ធ

គោលដៅទី៣:ពង្រឹងការចូលរួមរបស់អង្គការសហគមន៍ដែលធ្វើការងារជាមួយក្រុមបុរសស្រលាញ់បុរស និងស្រីស្រស់ នៅក្នុងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍

| | |
|---|---|
| ១ | រៀបចំប្រមូលរបាយការណ៍ជាមួយអង្គការដែលធ្វើការងារជាមួយក្រុមបុរសស្រលាញ់បុរស និងស្រីស្រស់ |
| ២ | រៀបចំផ្លាស់ប្តូរបទពិសោធន៍តាមរយៈកម្មសិក្សា ឬការចូលរួមកិច្ចប្រជុំនានាជាមួយអ្នកពាក់ព័ន្ធ |

យុទ្ធសាស្រ្តទី៤:លើកកំពស់លើការប្រមូល និងប្រើប្រាស់ព័ត៌មានជាយុទ្ធសាស្រ្ត

គោលដៅទី៤:ត្រួតពិនិត្យ និងតាមដានកម្មវិធីក្រុមបុរសស្រលាញ់បុរស និងស្រីស្រស់ ត្រូវបានកែលំអរ និងវាយតម្លៃសមត្ថភាព ប្រសិទ្ធភាព និងផលប៉ះពាល់នៃបទអន្តរាគមន៍

| | |
|---|---|
| ១ | ចុះត្រួតពិនិត្យ និងប្រមូលទិន្នន័យ ព័ត៌មានពីអង្គការក្រុមបុរសស្រលាញ់បុរស និងស្រីស្រស់ អ្នកផ្តល់សេវា និងសហគមន៍ក្រុមបុរសស្រលាញ់បុរស និងស្រីស្រស់ផ្ទាល់ |
| ២ | បង្កើតទម្រង់ប្រមូលទិន្នន័យសម្រាប់ត្រីមាសនីមួយៗ |
| ៣ | ជំរុញឱ្យស្ថាប័នធ្វើការងារជាមួយបុរសស្រលាញ់បុរស និងស្រីស្រស់ពង្រឹងការអនុវត្តន៍ការងារថ្នាក់សហគមន៍(សមត្ថភាព ប្រាក់ឧបត្ថម្ភ គ្រឿងលើកទឹកចិត្ត) |

| | |
|---|---|
| ៤ | រៀបចំកិច្ចប្រជុំ ឬវេទិការផ្លាស់ប្តូរយោបល់ជាមួយអង្គការពាក់ព័ន្ធ គ្លីនិក និង មណ្ឌលសុខភាព ដើម្បីផ្លាស់ប្តូរយោបល់ និងព័ត៌មាន |
| ៥ | រៀបចំកិច្ចប្រជុំត្រីមាសក្រុមការងារបច្ចេកទេសថ្នាក់ជាតិបុរសស្រលាញ់បុរស និង ស្រីស្រស់ |
| ៦ | រៀបចំកិច្ចប្រជុំបូកសរុបការងារប្រចាំឆ្នាំ របស់ក្រុមការងារលេខាធិការដ្ឋានប្រចាំ ឆ្នាំ២០១៦ |

## ឧបសម្ព័ន្ធ១៖ ការប៉ាន់ស្មានចំនួនបុរសស្រលាញ់បុរស (ចន្លោះអាយុ១៥-៤៩ឆ្នាំ) នៅក្នុងប្រទេសកម្ពុជា ឆ្នាំ២០១៤

| ឈ្មោះខេត្ត | តំបន់ប្រជុំជន | តំបន់ជនបទ | សរុប |
|---|---|---|---|
| ភ្នំពេញ | ៦៨២៣ | អត់មាន | ៦៨២៣ |
| បាត់ដំបង | ១៨៦៨ | ៩៦៣ | ២៨៣១ |
| បន្ទាយមានជ័យ | ១៣៧៥ | ៧៥០ | ២១២៥ |
| សៀមរាប | ១២២៨ | ៩៣០ | ២១៥៨ |
| កំពង់ឆ្នាំង | ៣៩៣ | ៦១៥ | ១០១០ |
| កំពងស្ពឺ | ៥៨៨ | ៧៨៣ | ១៣៧១ |
| កណ្តាល | ៥២៧ | ១៥០១ | ២០២៨ |
| ព្រៃវែង | ១៣០ | ១០៨៥ | ១២១៥ |
| កំពង់ចាម | ៣៧៣ | ២៣៥៨ | ២៧៣១ |
| ព្រះសីហនុ | ២៧៣ | ១៧២ | ៤៤៥ |
| ស្វាយរៀង | ១៣៥ | ៧៦២ | ៨៩៧ |
| កោះកុង | ១៣៧ | ១៤១ | ២៧៨ |
| ឧត្តមានជ័យ | ៦៣៦ | ១១៥ | ៧៥០ |
| ពោធិ៍សាត់ | ៣១១ | ៤៩៥ | ៨០៧ |
| កំពង់ធំ | ២៧៦ | ៨៦១ | ១១៣៧ |
| តាកែវ | ២៣៦ | ១២៧០ | ១៥០៦ |
| មណ្ឌលគីរី | ៥០ | ៦៣ | ១១៣ |
| កំពត | ១៨៣ | ៨២៧ | ១០១០ |

| ឈ្មោះខេត្ត | តំបន់ប្រជុំជន | តំបន់ជនបទ | សរុប |
|---|---|---|---|
| ប៉ៃលិន | ១៦១ | ៤៧ | ២០៨ |
| ក្រចេះ | ១៥៧ | ៣៩០ | ៥៤៧ |
| ស្ទឹងត្រែង | ១៤៧ | ១០៤ | ២៥១ |
| រតនៈគីរី | ១១៧ | ១៥៧ | ២៧៤ |
| ព្រះវិហារ | ៨៨ | ២០១ | ២៨៩ |
| កែប | ៥១ | ៣៦ | ៨៨ |
| *សរុប* | *១៦២៦៣* | *១៤៦២៧* | *៣០៨៩១* |

**ឧបសម្ព័ន្ធ២៖ ចំនួនក្រុមបុរសស្រលាញ់បុរស និងស្រីស្រស់ គ្របដណ្តប់ដោយអង្គការដៃគូ ឆ្នាំ២០១៥**

| ល.រ | រាជធានី ខេត្ត | ចំនួនបុរសស្រលាញ់បុរស (MSM) | ចំនួនស្រីស្រស់(TG) | ចំនួនសរុប | អង្គការដែលធ្វើការជាមួយ MSM&TG |
|---|---|---|---|---|---|
| ១ | ភ្នំពេញ | ៥០៨៨ | ១៥២៩ | ៦៦១៧ | **MHSS (MSM:1114)**<br>**MHC (MSM: 1889, TG: 745), SIT (187, TG: 106), KHEMERA (MSM:891, TG: 315), CSSD (MSM: 1005, TG: 363** |
| ២ | សៀមរាប | ៨៥៥ | ៣១១ | ១១៦៦ | **MHC** |
| ៣ | បាត់ដំបង | ២៧៥៤ | ៣០៣ | ៣០៥៧ | **MHSS** |
| ៤ | បន្ទាយមានជ័យ | ១៧៨០ | ១៨៤ | ១៩៦៤ | **MHSS** |
| ៥ | ពោធិសាត់ | ៥៦៨ | ៥៩ | ៦២៧ | **MHSS** |
| ៦ | កំពង់ឆ្នាំង | ៥៤៨ | ៥៧ | ៦០៥ | **MHSS** |
| ៧ | កំពង់ស្ពឺ | ៤៩៦ | ៥១ | ៥៤៧ | **MHSS** |
| ៨ | ព្រះសីហនុ | ២៥០ | ៥០ | ៣០០ | **KHEMERA** |

| | | | | | |
|---|---|---|---|---|---|
| ៩ | កោះកុង | ៣០០ | ៣៣ | ៣៣៣ | **MHC** |
| ១០ | កំពង់ចាម | ៤៦១ | ៥២ | ៥១៣ | **MHC** |
| ១១ | កណ្ដាល | ៨៣៣ | ៣៧២ | ១២០៥ | **SIT (MSM:៤៣៤ TG:២០៣); MHC (MSM:៣៩៩ TG:១៦៩)** |
| ១២ | ព្រៃវែង | ៤៩៧ | ៤៩ | ៥៤៦ | **MHSS** |
| ១៣ | កំពង់ធំ | ៥១៨ | ៥៤ | ៥៧២ | **MHSS** |
| ១៤ | ប៉ៃលិន | ២៩២ | ៣៩០ | ៦៨២ | **MHSS** |
| | សរុប | ១៤៤០៧ នាក់ | ៣១២២ នាក់ | ១៧៥២៩ នាក់ | |

CAMBODIANS AND AMERICANS IN PARTNERSHIP TO FIGHT HIV/AIDS
PEPFAR

USAID
ជំនួយពីពលរដ្ឋអាមេរិក

FLAGSHIP
KHANA fhi360 psi